# ព្រះរាជក្រឹត្យ

នស/រកត/១១១៧/១០៩៥

## ស្ដីពី

## ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិគស្តុភារកម្ម

## យើង

## ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សម្ពោហាភាស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០១៣ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ ២០១៦ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

## ត្រាស់បង្គាប់
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតក្រុមប្រឹក្សាជាតិភស្តុភារកម្ម ដែលសរសេរជាអក្សរកាត់ថា **ក.ជ.ភ.** ជាសេនាធិការឱ្យរាជរដ្ឋាភិបាល ដើម្បីដឹកនាំ គ្រប់គ្រង និងជំរុញការអភិវឌ្ឍវិស័យភស្តុភារកម្មនៃព្រះរាជាណាចក្រកម្ពុជា។

ភស្តុភារកម្ម សំដៅដល់ការរួមបញ្ចូលគ្នាក្នុងការរៀបចំបែបបទ ការចាត់ចែង ការសម្របសម្រួល និងការអភិវឌ្ឍ ធាតុសំខាន់ដូចខាងក្រោម៖

១- ប្រព័ន្ធសម្របសម្រួល បែបបទទំនិញចេញ ចូល និងការដឹកជញ្ជូនឆ្លងកាត់ព្រំដែន។

២- ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូននិងពាណិជ្ជកម្ម មានជាអាទិ៍ ផ្លូវគោក ផ្លូវដែក ផ្លូវសមុទ្រ ផ្លូវទឹក ផ្លូវអាកាស កំពង់ផែ។

៣- សមត្ថភាពនិងគុណភាពនៃស្ថាប័នផ្តល់សេវាភស្តុភារកម្ម មានជាអាទិ៍ ស្ថាប័នដែលពាក់ព័ន្ធនឹងការធ្វើចរាចរណ៍ ការទុកដាក់ ការចែកចាយ និងការឆ្លងកាត់ទំនិញ។

៤- ការផ្តល់សេវាភស្តុភារកម្មទាន់ពេលវេលានិងប្រកបដោយទំនុកចិត្ត។

៥- ភាពងាយស្រួលក្នុងការដឹកជញ្ជូនទំនិញប្រកបដោយតម្លៃប្រកួតប្រជែងទៅទីផ្សារអន្តរជាតិ។

៦- ប្រព័ន្ធព័ត៌មានតាមដានរំហូរនៃការដឹកជញ្ជូនទំនិញនិងអ្នកដំណើរ។

## ជំពូកទី២
## សមាសភាពរបស់ ក.ជ.ភ.

**មាត្រា២ .-**

**ក.ជ.ភ.** មានសមាសភាព ដូចខាងក្រោម៖

| | |
|---|---|
| - ឧបនាយករដ្ឋមន្ត្រី ១រូប | ប្រធាន |
| - រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន | អនុប្រធានប្រចាំការ |
| - រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

- រដ្ឋមន្ត្រីក្រសួងផែនការ — សមាជិក
- រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម — សមាជិក
- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា — សមាជិក
- អគ្គលេខាធិការឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ — សមាជិក។

**ក.ជ.ភ.** អាចមានសមាសភាពបន្ថែម តាមការចាំបាច់។

សមាសភាពជាក់ស្តែងរបស់ **ក.ជ.ភ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣
## តួនាទីនិងភារកិច្ចរបស់ ក.ជ.ភ.

**មាត្រា៣ .-**

**ក.ជ.ភ.** មានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- ផ្តល់គោលការណ៍ណែនាំ ក្នុងការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព និងលិខិតបទដ្ឋានគតិយុត្ត ក្នុងការគ្រប់គ្រងប្រតិបត្តិ និងអភិវឌ្ឍវិស័យភស្តុភារកម្មនៃព្រះរាជាណាចក្រកម្ពុជា
- សម្របសម្រួលនិងត្រួតពិនិត្យចុងក្រោយ នូវយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព និងលិខិតបទដ្ឋានគតិយុត្តវិស័យភស្តុភារកម្ម មុននឹងដាក់ជូនរាជរដ្ឋាភិបាលពិនិត្យនិងសម្រេច
- កំណត់អាទិភាពការអភិវឌ្ឍវិស័យភស្តុភារកម្ម រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង
- កៀរគរការគាំទ្រធនធានហិរញ្ញវត្ថុ បច្ចេកទេស និងធនធានមនុស្ស ដែលជាតម្រូវការចាំបាច់ ដើម្បីជំរុញការអភិវឌ្ឍវិស័យភស្តុភារកម្ម
- ត្រួតពិនិត្យការអនុវត្តការងារ និងផ្តល់អនុសាសន៍ណែនាំ ដើម្បីដោះស្រាយបញ្ហានានានៅក្នុងវិស័យភស្តុភារកម្ម
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ គ.ជ.ត.

**មាត្រា៤ ._**

**គ.ជ.ត.** ត្រូវរៀបចំកិច្ចប្រជុំរបស់ខ្លួនយ៉ាងតិច១(មួយ)ដងក្នុងមួយឆ្នាំ តាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីចាំបាច់ **គ.ជ.ត.** អាចប្រជុំជាវិសាមញ្ញបាន។

ប្រធានអាចផ្ទេរសិទ្ធិជូនអនុប្រធាន ដើម្បីដឹកនាំការប្រជុំតាមការប្រគល់សិទ្ធិពីប្រធាន។

ក្នុងករណីអវត្តមាន សមាជិក **គ.ជ.ត.** ត្រូវចាត់តំណាងដែលមានសិទ្ធិសម្រេចចូលរួមប្រជុំជំនួស។

ប្រធាន **គ.ជ.ត.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័ន ឥស្សរជន ដៃគូអភិវឌ្ឍ វិស័យឯកជន អ្នកជំនាញការជាតិ អន្តរជាតិ ដើម្បីចូលរួមផ្តល់យោបល់ក្នុងករណីចាំបាច់។

បែបបទនិងនីតិវិធីការងារ ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ **គ.ជ.ត.**។

**មាត្រា៥ ._**

**គ.ជ.ត.** មានគណៈកម្មាធិការជាតិភស្តុភារកម្ម ដែលសរសេរជាអក្សរកាត់ថា **គ.ជ.ត.** ជាអង្គភាពប្រតិបត្តិ ដើម្បីគ្រប់គ្រង សម្របសម្រួល ប្រតិបត្តិ និងអភិវឌ្ឍវិស័យភស្តុភារកម្ម ដែលមានសមាសភាព ដូចខាងក្រោម៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម១រូប | អនុប្រធាន |
| - អគ្គលេខាធិការនៃគណៈកម្មាធិការវិនិយោគកម្ពុជា | អនុប្រធាន |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងឧស្សាហកម្មនិងសិប្បកម្ម១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងផែនការ១រូប | សមាជិក |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

- រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងបរិស្ថាន១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងយុត្តិធម៌១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងសុខាភិបាល១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងទេសចរណ៍១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ១រូប សមាជិក
- រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល១រូប សមាជិក
- អគ្គលេខាធិការគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា សមាជិក
- អគ្គលេខាធិការរងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ១រូប សមាជិក
- អគ្គលេខាធិការរងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា១រូប សមាជិក
- អគ្គទេសាភិបាលរងធនាគារជាតិនៃកម្ពុជា១រូប សមាជិក
- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត សមាជិក
- អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា សមាជិក
- អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ សមាជិក
- អគ្គនាយកនៃអគ្គនាយកដ្ឋានកាំកុងត្រូល សមាជិក
- អគ្គនាយកកំពង់ផែស្វយ័តក្រុងព្រះសីហនុ សមាជិក
- អគ្គនាយកកំពង់ផែស្វយ័តភ្នំពេញ សមាជិក
- អគ្គនាយកភ្នាក់ងារកម្ពុជានាវាចរ (កាំសាប) សមាជិក
- ប្រធានសភាពាណិជ្ជកម្មកម្ពុជា សមាជិក
- តំណាងគ្រឹះស្ថានឧត្តមសិក្សាដែលពាក់ព័ន្ធវិស័យភស្តុភារកម្ម សមាជិក
- អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារកម្មក្រសួងសាធារណការនិងដឹកជញ្ជូន ជាសមាជិកអចិន្ត្រៃយ៍។

**គ.ប.ភ.** អាចមានសមាសភាពបន្ថែម តាមការចាំបាច់។

សមាសភាពជាក់ស្តែងនៃ **គ.ប.ភ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

**មាត្រា៦ .-**

**គ.ជ.ត.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ដឹកនាំរៀបចំបង្កើតនូវឯកសារគោលនយោបាយ យុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព និងលិខិតបទដ្ឋានគតិយុត្ត ក្នុងការគ្រប់គ្រង ប្រតិបត្តិ និងអភិវឌ្ឍវិស័យភស្តុភារកម្មនៃព្រះរាជាណាចក្រកម្ពុជា ដោយធ្វើការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធទាំងអស់ដើម្បីដាក់ជូន **គ.ជ.ត.** ពិនិត្យនិងសម្រេច
- សម្របសម្រួលនិងជំរុញការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព និងលិខិតបទដ្ឋានគតិយុត្តរបស់វិស័យភស្តុភារកម្ម ឱ្យមានប្រសិទ្ធភាព ប្រសិទ្ធផល និងនិរន្តរភាព
- ជំរុញការអនុវត្តផែនការនានាដែលទាក់ទងនឹងវិស័យភស្តុភារកម្មអន្តរជាតិក្នុងក្របខ័ណ្ឌអាស៊ាននិងពិភពលោក
- ពិនិត្យនិងលើកសំណើកែសម្រួលឬធ្វើវិសោធនកម្មបទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹងវិស័យភស្តុភារកម្ម ឲ្យមានសង្គតិភាពទៅនឹងលិខិតបទដ្ឋានគតិយុត្ត ដែលមានជាធរមាន
- ស្វែងរកធនធានហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង ប្រតិបត្តិ ទ្រទ្រង់ និងលើកកម្ពស់ជំរុញការអភិវឌ្ឍវិស័យភស្តុភារកម្ម
- រៀបចំទិន្នន័យគោលនិងសូចនាករសម្រាប់ការត្រួតពិនិត្យនិងវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរបស់បណ្តាក្រសួង ស្ថាប័ន និងវិស័យឯកជនដែលមានចែងក្នុងផែនការមេភស្តុភារកម្ម
- ធ្វើរបាយការណ៍សកម្មភាពការងារជូន **គ.ជ.ត.**
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែល **គ.ជ.ត.** ប្រគល់ជូន។

**មាត្រា៧ .-**

**គ.ជ.ត.** ត្រូវបង្កើតក្រុមការងារបង្គោលតាមក្រសួង ស្ថាប័ន និងវិស័យឯកជន រៀងៗខ្លួន ដើម្បីសហការជាមួយលេខាធិការដ្ឋានរបស់ **គ.ជ.ត.**។

**មាត្រា៨ .-**

**គ.ជ.ត.** ត្រូវរៀបចំកិច្ចប្រជុំរបស់ខ្លួនយ៉ាងតិច២(ពីរ)ដងក្នុងមួយឆ្នាំ តាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីចាំបាច់ **គ.ជ.ត.** អាចប្រជុំជាវិសាមញ្ញបាន។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ក្នុងករណីអវត្តមាន សមាជិក **គ.ជ.ត.** ត្រូវចាត់តំណាងដែលមានសិទ្ធិសម្រេច ចូលរួមប្រជុំជំនួស។ ប្រធានអាចផ្ទេរសិទ្ធិជូនអនុប្រធាន ដើម្បីដឹកនាំការប្រជុំតាមការប្រគល់សិទ្ធិពីប្រធាន។

ប្រធាន **គ.ជ.ត.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័ន ឥស្សរជន ដៃគូអភិវឌ្ឍ វិស័យឯកជន អ្នកជំនាញការជាតិ អន្តរជាតិ ដើម្បីចូលរួមផ្តល់យោបល់ ក្នុងករណីចាំបាច់។

បែបបទនិងនីតិវិធីការងារត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ **គ.ជ.ត.** ។

**មាត្រា៩ .-**

**គ.ជ.ត.** មានសិទ្ធិបង្កើតក្រុមការងារនិងក្រុមពិគ្រោះយោបល់ ដើម្បីជួយបំពេញការងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព។

សមាសភាពនិងតួនាទីភារកិច្ចរបស់ក្រុមការងារនិងក្រុមពិគ្រោះយោបល់ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ជ.ត.**។

**មាត្រា១០ .-**

គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវចូលរួមសហការ និងមានភារកិច្ចផ្តល់ឯកសារព័ត៌មានពាក់ព័ន្ធនានាជូនដល់ **គ.ជ.ត.** ។

**មាត្រា១១ .-**

ក្រសួងសាធារណការនិងដឹកជញ្ជូន មានអគ្គនាយកដ្ឋានភស្តុភារកម្ម ជាលេខាធិកាដ្ឋាន **គ.ជ.ត.** ដែលមានតួនាទីនិងភារកិច្ចបន្ថែមដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពការងារនិងគម្រោងថវិការបស់លេខាធិការដ្ឋាន
- បំពេញការងាររដ្ឋបាលនិងហិរញ្ញវត្ថុជូន **គ.ជ.ត.**
- ប្រមូលចងក្រងឯកសារគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព លិខិតបទដ្ឋានគតិយុត្តនានា ដែលទាក់ទងនឹងវិស័យភស្តុភារកម្ម
- ដឹកនាំនិងសហការជាមួយក្រុមការងារឬមន្ត្រីបង្គោលរបស់ក្រសួង ស្ថាប័នដែលមានសមាសភាពក្នុង **គ.ជ.ត.** និងភាគីពាក់ព័ន្ធនានា ដើម្បីជួយរៀបចំ តាមដាន ការអនុវត្ត និងអភិវឌ្ឍ៖
  - ក- ផែនការមេ យុទ្ធសាស្ត្រ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការងារភស្តុភារកម្ម។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

ខ- ផែនការបណ្តុះបណ្តាលធនធានមនុស្សនិងផ្សព្វផ្សាយព័ត៌មានក្នុងវិស័យ ភស្តុភារកម្ម។

គ- ផែនការផ្គត់ផ្គង់ធនធានចាំបាច់នានា សម្រាប់ដំណើរការការងារក្នុងវិស័យ ភស្តុភារកម្ម។

ឃ- ស្រាវជ្រាវនិងអភិវឌ្ឍវិស័យភស្តុភារកម្ម។

ង- ផែនការធ្វើសមាហរណកម្មប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យាភស្តុភារកម្ម។

ច- ផែនការលើកកម្ពស់និងគាំទ្រដល់វិស័យឧស្សាហកម្មភស្តុភារកម្មជាតិ។

ឆ- ផែនការធានាសុវត្ថិភាពក្នុងចង្វាក់ផ្គត់ផ្គង់នៃវិស័យភស្តុភារកម្ម។

ជ- នវានុវត្តភាពក្នុងវិស័យភស្តុភារកម្ម។

- ពិនិត្យ វាយតម្លៃអំពីសង្គតិភាពនិងភាពគ្រប់ជ្រុងជ្រោយ ព្រមទាំងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រ គោលនយោបាយ និងកម្មវិធីនានាពាក់ព័ន្ធនឹងវិស័យភស្តុភារកម្ម និងលើកសំណើផ្សេងៗដាក់ជូន **គ.ជ.ភ.** ដើម្បី ពិនិត្យសម្រេច
- ធ្វើរបាយការណ៍សកម្មភាពការងារ កំណត់ហេតុកិច្ចប្រជុំរបស់ **ក.ជ.ភ.**និង**គ.ជ.ភ.**
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែល **គ.ជ.ភ.** ប្រគល់ជូន។

**មាត្រា១២ .-**

**ក.ជ.ភ.** មានសិទ្ធិប្រើត្រារបស់ក្រសួងសាធារណការនិងដឹកជញ្ជូន សម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៥
## ប្រភពធនធាន

**មាត្រា១៣ .-**

**ក.ជ.ភ.** មានថវិកាដោយឡែករបស់ខ្លួន ដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងសាធារណការនិងដឹកជញ្ជូន។

**ក.ជ.ភ.** មានសិទ្ធិទទួលនិងចាត់ចែង ប្រើតាមនីតិវិធីច្បាប់ជាធរមាននូវមូលនិធិដែលបានមកពីប្រភពផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

ROYAUME DU CAMBODGE
ព្រះបរមរាជវាំង
LE MINISTRE DU PALAIS ROYAL

**មាត្រា១៥ .-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកត/១១១៧/១១១០

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន**
**ហត្ថលេខា**
**ស៊ុន ចាន់ថុល**

លេខ: ១០៩៧ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សយ សុខា**